# សង្កេតការណ៍

## ៣

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



# កាំង ហ្គេកអ៊ាវ ហៅឌុច

ខែតុលា ឆ្នាំ២០១១

## មាតិកា


សេចក្តីផ្តើម ១
យុត្តាធិការបុគ្គល ២
ការរួមបញ្ចូលគ្នានៃបទល្មើស ៦
ការកំណត់ទោស ១០
បណ្តឹងសាទុក្ខ ១៣
សេចក្តីថ្លែងចុងក្រោយ ១៤
សន្និដ្ឋាន ១៦



ក្រុមសង្កេតការណ៍ ៖
គីម ម៉ារីយ៉ាន, ឌី សុជាតា,
លីម ជ័យទត្ត និង ទាន ប្រាថ្នា



មជ្ឈមណ្ឌលឯកសារកម្ពុជា ◆ ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌ ◆ www.dccam.org



កាំង ហ្កេកអ៊ាវ ហៅ ឌុច និង និរសាឈ្មោះ សុខ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រូបថតប្រហែលក្នុងឆ្នាំ១៩៧៧ (ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# តើអង្គជំនុំជម្រះតុលាការកំពូលនឹងសម្រេចយ៉ាងដូចម្តេច ចំពោះករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច

*គីម ម៉ារីយ៉ាន, ឌី សុដាតា, លីម ជ័យទត្ត និង ចាន ប្រាថ្នា*

## សេចក្តីផ្តើម

ការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើសំណុំរឿងព្រហ្មទណ្ឌលេខ ០០១ ដែលមានជនជាប់ចោទ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានក្លាយជាការបើកទំព័រប្រវត្តិសាស្ត្រថ្មីមួយរបស់ប្រទេសកម្ពុជា ។

ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅឌុច គឺជាអតីតគ្រូបង្រៀនគណិតវិទ្យាម្នាក់ ដែលកើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ។[១] នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឌុច មានឋានៈជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរសន្តិសុខស-២១ ។

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចប្រកាសសាលក្រមផ្តន្ទាទោស ឌុច ឲ្យជាប់គុករយៈពេល៣៥ឆ្នាំ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។[២] ការផ្តន្ទាទោសដាក់គុករយៈពេល៣៥ឆ្នាំ គឺផ្អែកលើស្ថានសម្រាលទោសដែលតម្រូវឲ្យមានការកំណត់រយៈពេលជាក់លាក់មួយ ជាជាងការដាក់ទោសជនជាប់ចោទក្នុងគុកអស់មួយជីវិត ។ ស្ថានសម្រាលទាំងនោះរួមមាន កិច្ចសហការរបស់ជនជាប់ចោទជាមួយអង្គជំនុំជម្រះ ការទទួលស្គាល់នូវការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលជនជាប់ចោទបានប្រព្រឹត្ត ការសម្តែងវិប្បដិសារីនិងការសុំអភ័យទោសរបស់ជនជាប់ចោទ ។[៣] ក៏ប៉ុន្តែទោសនេះត្រូវបានកាត់បន្ថយរយៈពេល៥ឆ្នាំ សម្រាប់ទូទាត់ចំពោះការឃុំឃាំងជនជាប់ចោទខុសនីតិវិធីច្បាប់ដោយតុលាការយោធា និងរយៈពេល១១ឆ្នាំដែល ឌុច ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅក្នុងពន្ធនាគាររបស់តុលាការយោធា និងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។[៤] ភាគីទាំងអស់នៅក្នុងសំណុំរឿងនេះបានសម្រេចដាក់ពាក្យបណ្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូលប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ។

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានជូនដំណឹងអំពីការដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដោយសម្អាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់ស្ថានទម្ងន់គ្រប់គ្រាន់ក្នុងការផ្តន្ទាទោសលើជនជាប់ចោទ និងបានផ្តល់ស្ថានសម្រាលទោសហួសហេតុ ។ ឌុច គួរតែត្រូវផ្តន្ទាទោសបន្ថែមចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាអាទិ៍ ការដាក់ឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការសម្លាប់រង្គាល និងសកម្មភាពអមនុស្សធម៌ផ្សេងៗទៀតដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១ ។[៥]

នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ មេធាវីការពារក្តីឲ្យជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងគោលបំណងចង់ឲ្យអង្គជំនុំជម្រះតុលាការកំពូលលើកលែងការចោទប្រកាន់ទៅលើ

---

[១] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ប្រកាសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ករណី០០១ កថាខណ្ឌ ១ ។

[២] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ប្រកាសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ករណី០០១ កថាខណ្ឌ ៦៧៧ ។

[៣] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ប្រកាសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ករណី០០១ កថាខណ្ឌ ៦១០ ។

[៤] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ប្រកាសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ករណី០០១ កថាខណ្ឌ ៦៨០ ។

[៥] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារE ១៨៨/២ ។



កូនក្តីរបស់ខ្លួន ដោយអះអាងថា ឌុច មិនបានស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ។ ម្យ៉ាងទៀត ការផ្តន្ទាទោស ឌុច គួរតែអនុលោមតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ។[៦]

រីឯ ដើមបណ្តឹងរដ្ឋប្បវេណីវិញ មានដើមបណ្តឹងរដ្ឋប្បវេណីបីក្រុមក្នុងចំណោមបួនក្រុម បានដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមខាងលើ ដោយសារតែសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនត្រូវបានច្រានចោលដោយអង្គជំនុំជម្រះសាលាដំបូង និងស្នើសុំឲ្យមានការផ្តល់នូវសំណងផ្លូវចិត្ត និងសំណងសមូហភាពដែលមានលក្ខណៈសមរម្យជាងនេះ ។

អាស្រ័យដោយមានបណ្តឹងសាទុក្ខដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យ និងសិក្សាយ៉ាងល្អិតល្អន់មុននឹងធ្វើការប្រកាសបើកសវនាការលើបណ្តឹងសាទុក្ខនេះ ពីថ្ងៃទី២៨ រហូតដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១ ។ សវនាការលើបណ្តឹងសាទុក្ខនេះ អនុញ្ញាតឲ្យភាគីទាំងអស់ធ្វើការលើកឡើងនូវអំណះអំណាង និងសំណើសុំរបស់ខ្លួនមកកាន់អង្គជំនុំជម្រះតុលាការកំពូល ដើម្បីសម្រេចទាក់ទងទៅនឹងបញ្ហាមួយចំនួនដូចជា ៖

- យុត្តាធិការបុគ្គល
- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ
- ការកំណត់ទោស និង
- បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

## ១) យុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ឌុច មេធាវីការពារក្តីបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានការភាន់ច្រឡំចំពោះយុត្តាធិការបុគ្គលមកលើជនជាប់ចោទ ឌុច ហើយថាអង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំចំពោះការកំណត់ទោសមកលើកូនក្តីរបស់ខ្លួន ដោយមិនបានពិចារណាលើវិធាន៨៧(១) នៃវិធានផ្ទៃក្នុង និងមាត្រា៩៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ។ ពាក្យថាយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានន័យថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចអនុវត្តសិទ្ធិអំណាច ឬមានដែនសមត្ថកិច្ចក្នុងការនាំយកបុគ្គលណាម្នាក់ដែលស្ថិតក្រោមអំណាចរបស់ខ្លួនមកជំនុំជម្រះ នៅចំពោះមុខអង្គជំនុំជម្រះបាន ។ បុគ្គលដែលស្ថិតក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានកំណត់ដោយមាត្រា១ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានជាអាទិ៍ "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបាន

[៦] សេចក្តីជូនដំណឹងរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E១៨៨/៨ ។



និស្សិតកំពុងតម្រង់ជួរចូលបន្ទប់សវនាការ (ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រព្រឹត្តនៅក្នុងអំឡុងថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩» ។

### ក) អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំចំពោះយុត្តាធិការបុគ្គលមកលើ ឌុច

សហមេធាវីការពារក្តីរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំក្នុងការកំណត់យុត្តាធិការបុគ្គលមកលើជនជាប់ចោទ ឌុច ព្រោះជនជាប់ចោទរូបនេះមិនមែនជាបុគ្គលដែលស្ថិតក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចដែលបានចែងក្នុងមាត្រា១ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ និងមាត្រា១ និងមាត្រា២ នៃច្បាប់ស្តីពីការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមឡើយ ។[៧]

មេធាវីជនជាប់ចោទលើកឡើងថា ៖

ទី១) ជនជាប់ចោទ ឌុច មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋនៅក្នុងមន្ទីរស-២១ទេ ព្រោះបុគ្គលនេះគ្មានសិទ្ធិសម្រេចចំពោះការចាប់ខ្លួន និងសម្លាប់នរណាម្នាក់ឡើយ គ្រាន់តែទទួលបញ្ជាពីថ្នាក់លើរបស់ខ្លួនតែប៉ុណ្ណោះ ។[៨] សហមេធាវីបានអះអាងថា កូនក្តីរបស់ខ្លួនគ្មានសិទ្ធិក្នុងការសម្រេចអ្វីទាំងអស់ ក្រៅពីមានតួនាទីត្រឹមតែជាអ្នកចាំទទួលអ្នកទោសដែលបញ្ជូនមកពីគ្រប់ទីកន្លែងនៅទូទាំងប្រទេសដើម្បីសួរចម្លើយ ហើយក៏យកទៅសម្លាប់ចោលតាមបញ្ជារបស់ថ្នាក់លើ ។[៩] ជនជាប់ចោទ ឌុច មិនមានសិទ្ធិផ្តល់យោបល់ដល់បក្សកុម្មុយនីស្តកម្ពុជាចំពោះបញ្ហាសន្តិសុខជាតិទេ[១០] ហើយអ្នកដែលមានសិទ្ធិសម្រេចក្នុងការសម្លាប់គឺមនុស្សដែលគណៈកម្មាធិការមជ្ឈិមបានប្រគល់សិទ្ធិអំណាចឲ្យសម្លាប់ដូចបានកំណត់ក្នុងសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ។[១១] សហមេធាវីការពារក្តីបានលើកឡើងទៀតថា ការទទួលខុសត្រូវរបស់បុគ្គលម្នាក់ គឺផ្អែកលើឋានានុក្រមរបស់បុគ្គលនោះដែលត្រូវបានកំណត់ដោយច្បាប់ ។ បើបុគ្គលនោះមានឋានានុក្រមខ្ពស់គឺមានអំណាចខ្ពស់ក្នុងការចេញបញ្ជា និងសម្រេចឲ្យអនុវត្តបញ្ជា ហើយក៏មានការទទួលខុសត្រូវខ្ពស់ចំពោះសេចក្តីសម្រេចរបស់ខ្លួនដែរ ។[១២] សហមេធាវីបានសន្និដ្ឋានថា តាមតួនាទីរបស់ជនជាប់ចោទរូបនេះអាចបញ្ជាក់ឲ្យឃើញថា កូនក្តីរបស់ខ្លួនមិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតទេ ។

---

[៧] សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌទី៤ ។

[៨] សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌទី៣១និង៣៣ ។

[៩] សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌទី២៥ ។

[១០] សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌទី២៦ ។

[១១] សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌទី៥២-៥៤ ។

[១២] សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌទី៣៣ ។

ទី២) កិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការបញ្ចប់ជម្លោះនយោបាយ បានហាមមិនឲ្យបង្កើតច្បាប់ដើម្បីកាត់ទោសរាល់អំពើល្មើសដែលប្រព្រឹត្តក្នុងអតីតកាល ។[១៣]

ទី៣) មាត្រា ៥ នៃច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់បានទុករយៈពេល៦ខែ ក្រោយពីការចូលជាធរមានដើម្បីឲ្យខ្មែរក្រហមវិលត្រឡប់ចូលមករួមរស់នៅក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលកម្ពុជាដោយមិនយកទោសពៃរ៍ចំពោះបទល្មើសដែលបានប្រព្រឹត្ត ។ សហមេធាវីបានអះអាងថាចំពោះជនជាប់ចោទ ឌុច បានចុះចូលជាមួយនឹងរាជរដ្ឋាភិបាលរយៈពេល ២ឆ្នាំមុនច្បាប់នេះចូលជាធរមាន ។[១៤]

ទី៤) ជនជាប់ចោទ ឌុច គប្បីរួចផុតពីការចោទប្រកាន់ដោយតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដូចប្រធានគុកដទៃៗទៀតដែរ ។ សហមេធាវីការពារក្តី បានអះអាងថា កូនក្តីរបស់ខ្លួនមិនស្ថិតនៅក្នុងប្រភេទមនុស្សដែលត្រូវជំនុំជម្រះទោសដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ព្រោះជនជាប់ចោទរូបនេះមិនមានតំណែងខ្ពស់នៅក្នុងរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែបុគ្គលនេះគ្រាន់តែជាប្រធានគុកមួយរូបប៉ុណ្ណោះនៅក្នុងចំណោមប្រធានគុកប្រហែល២០០ ។ ដូចនេះ ប្រសិនបើប្រធានមន្ទីរឃុំឃាំងផ្សេងៗទៀតមិនត្រូវបាននាំយកមកកាត់ទោសទេ អង្គជំនុំជម្រះមួយនេះ ក៏មិនអាចកាត់ទោសកូនក្តីរបស់ខ្លួនដែរ ។[១៥]

សរុបសេចក្តីមក បញ្ហាដែលមេធាវីការពារក្តីបានលើកឡើងជាសំខាន់នោះគឺថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមានសិទ្ធិអំណាចនៅក្នុងការចោទប្រកាន់លើជនជាប់ចោទ ឌុច ដោយសារតែជនជាប់ចោទរូបនេះមិនស្ថិតនៅក្នុងរចនាសម្ព័ន្ធថ្នាក់ដឹកនាំជាន់ខ្ពស់ ឬអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ ។[១៦]

ឆ្លើយតបទៅនឹងការលើកឡើងរបស់សហមេធាវីការពារក្តី សហព្រះរាជអាជ្ញាបានលើកឡើងថា មេធាវីការពារក្តីមានភាពយឺតយ៉ាវក្នុងការលើកឡើងពីភាពគ្មានយុត្តាធិការលើជនជាប់ចោទ ឌុច ដូចនេះអង្គជំនុំជម្រះសាលាដំបូងមិនចាំបាច់ពិចារណាលើបញ្ហាយុត្តាធិការឡើយ ។ សហព្រះរាជអាជ្ញាបានបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តយ៉ាងត្រឹមត្រូវតាមវិធាន៨៩ នៃវិធានផ្ទៃក្នុងដែលតម្រូវឲ្យភាគីលើកពីបញ្ហាយុត្តាធិការនៅក្នុងសវនាការជំនុំជម្រះបឋម ។[១៧] នៅពេលសវនាការបឋម ប្រធានអង្គជំនុំជម្រះសាលាដំបូងបានស្នើឲ្យភាគីលើកឡើងពីអញ្ញត្រកម្មដូចជាយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះលើជនជាប់ចោទ ប៉ុន្តែភាគីមេធាវីការពារក្តីរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានខកខានក្នុងការលើកឡើងពីអញ្ញត្រកម្មនេះ ហើយលើកតែអំពីបញ្ហាបទល្មើសជាតិតែប៉ុណ្ណោះ ។[១៨]

ពាក់ព័ន្ធនឹងការលើកឡើងរបស់មេធាវីការពារក្តី ឌុច ដែលថាអង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំក្នុងការចាត់ថ្នាក់ជនជាប់ចោទ ឌុច ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខស-២១ សហព្រះរាជអាជ្ញាបានលើកឡើងថា សាលាដំបូងមិនមានការភាន់ច្រឡំក្នុងការកំណត់ថាជនជាប់ចោទ ឌុច ជាអ្នកទទួលខុសត្រូវម្នាក់ក្នុងចំណោម «អ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម» ឡើយ ។[១៩] ជនជាប់ចោទ ឌុច ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅមន្ទីរស-២១ ដោយសារមន្ទីរនេះគឺជាមន្ទីរតែមួយគត់ដែលឃុំឃាំងមេដឹកនាំជាន់ខ្ពស់របស់

---

[១៣] សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌទី១៤ ។

[១៤] សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌទី១៥ ។

[១៥] សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌទី៣៩ ។

[១៦] សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌទី២២ និង សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ លេខ F/14/4 កថាខណ្ឌទី៣ ។

[១៧] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ លេខ F/14/4 កថាខណ្ឌទី១៤ ។

[១៨] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ លេខ F/14/4 កថាខណ្ឌទី១៥ និង១៦ ។

[១៩] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ លេខ F/14/4 កថាខណ្ឌទី១១ ។

កម្ពុជាប្រជាធិបតេយ្យ និងជនបរទេស ។ យុទ្ធជននិងកម្មាភិបាលខ្មែរក្រហមជាច្រើនត្រូវបានឃុំខ្លួននៅទីនោះ ។ ជនជាប់ចោទរូបនេះទទួលខុសត្រូវចំពោះបុគ្គលិកច្រើនជាង២៣០០នាក់ ហើយមន្ទីរឃុំឃាំងនេះមានអំណាចចាប់មនុស្សនៅទូទាំងប្រទេសទៀតផង ។ កម្មាភិបាលជាច្រើនត្រូវបានបញ្ជូនមកមន្ទីរស-២១ និងសម្លាប់នៅទីនេះ ។ ជនជាប់ចោទ ឌុច គឺជាអ្នករាយការណ៍ដោយផ្ទាល់ទៅគណៈកម្មាធិការអចិន្ត្រៃយ៍អំពីការចាប់ឃុំ ការសួរចម្លើយ និងការសម្លាប់អ្នកទោសនៅមន្ទីរស-២១ ។ ជនជាប់ចោទរូបនេះក៏ជាអ្នកបង្កើតបទបញ្ជាសម្រាប់អនុវត្តនៅមន្ទីរស-២១ ដែលធ្វើឲ្យមន្ទីរនេះមានដំណើរការប្រកបដោយប្រសិទ្ធភាព ។ សហព្រះរាជអាជ្ញាបានបន្ថែមដោយយោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានរកឃើញថា ជនជាប់ចោទ ឌុច ពិតជាមានអំណាចមួយចំនួនក្នុងការសម្រេចថានរណាម្នាក់ត្រូវចាប់ខ្លួន និងក្រោយមកសម្លាប់ចោល និងមានសកម្មភាពយ៉ាងសកម្មក្នុងការពង្រីកការបោសសម្អាតនៅឆ្នាំចុងក្រោយនៃរបបនោះ ព្រមទាំងបានបំពេញសកម្មភាពក្នុងការដឹកនាំមន្ទីរស-២១ យ៉ាងខ្នះខ្នែង និងមានប្រសិទ្ធភាពបំផុត ។[២០]

ចំពោះការលើកឡើងរបស់មេធាវីការពារក្ដីដែលថា មិនត្រូវធ្វើការចោទប្រកាន់ជនជាប់ចោទ ឌុច ឡើយដោយសារតែប្រធានគុកផ្សេងៗទៀតមិនត្រូវបានចោទប្រកាន់ សហព្រះរាជអាជ្ញាបានតបវិញថា អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ច្បាប់និងកិច្ចព្រមព្រៀងស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានចងកាតព្វកិច្ចឲ្យតុលាការត្រូវតែធ្វើការជំនុំជម្រះគ្រប់ជនដៃដល់នៃរបបកម្ពុជាប្រជាធិបតេយ្យទាំងអស់ឡើយ ។ សហព្រះរាជអាជ្ញាធ្វើការចោទប្រកាន់លើជនណាម្នាក់ គឺពឹងផ្អែកទៅលើភស្តុតាងដែលមានស្រាប់ ភាពធ្ងន់ធ្ងរ និងភាពសាហាវយង់ឃ្នងនៃបទល្មើស ។[២១]

### ១) ការភាន់ច្រឡំចំពោះការផ្ដន្ទាទោសទៅលើជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច


ឌុច ក្នុងបន្ទប់សវនាការ (រូបថត : អ.វ.ត.ក)

សហមេធាវីការពារក្ដីរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានលើកឡើងថា ភស្តុតាងមួយចំនួនមិនត្រូវបានលាតត្រដាងដើម្បីឲ្យតុលាការធ្វើការសម្រេចថា តើជនជាប់ចោទ ឌុច ស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួនឬយ៉ាងណាទេ ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងសម្រេចផ្ដន្ទាទោស ជនជាប់ចោទ ឌុច គឺពឹងផ្អែកតែទៅលើភស្តុតាងដាក់បន្ទុកលើបទល្មើសទាំងស្រុង ហើយខកខានមិនបានពិនិត្យមើលលើភស្តុតាងដោះបន្ទុក និងលើយុត្តាធិការបុគ្គល ។[២២] អង្គជំនុំជម្រះសាលាដំបូងមិនបានធ្វើការកោះហៅសាក្សីមួយចំនួនដែលជនជាប់ចោទ ឌុច ស្នើសុំឲ្យកោះហៅ

---

២០ សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្ដឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ កថាខណ្ឌទី៣៨-៣៩ ។

២១ សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្ដឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ លេខ F/14/4 កថាខណ្ឌទី៤៤ ។

២២ សារណាបណ្ដឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌទី៦៩ ។

មកធ្វើសក្ខីកម្មដើម្បីដោះបន្ទុកដែលសាក្សីទាំងនោះសុទ្ធតែមានឋានៈខ្ពស់ជាងខ្លួនដូចជា នួន ជា ជាដើម ។ សាក្សីរូបនេះអាចបញ្ជាក់ថា ជនជាប់ចោទ ឌុច ជាអ្នកទទួលខុសត្រូវទាប ប៉ុន្តែការខកខានក្នុងការកោះហៅនេះ ធ្វើឲ្យអង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំក្នុងការកំណត់យុត្តាធិការបុគ្គលមកលើជនជាប់ចោទ ឌុច ។ ឆ្លើយតបទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាដែលថា ឌុច មានការខកខានក្នុងការលើកឡើងពីអញ្ញត្រកម្ម ដូចមានកំណត់ក្នុងវិធាន៨៩នៃវិធានផ្ទៃក្នុង មេធាវីការពារក្តីរបស់ជនជាប់ចោទ ឌុច បានតបវិញថា ខ្លួនបានធ្វើការលើកឡើងពីអញ្ញត្រកម្មនេះនៅពេលសវនាការ ព្រមទាំងបានធ្វើសេចក្តីសន្និដ្ឋានពីភាពគ្មានយុត្តាធិការបុគ្គលលើកូនក្តីរបស់ខ្លួននៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូង បានច្រានចោលមិនពិចារណា[២៣] លើអញ្ញត្រកម្មនេះ ។ មេធាវីបានបន្ថែមថា មូលហេតុដែលសាលាដំបូងច្រានចោលការលើកឡើងពីភាពគ្មានយុត្តាធិការរបស់មេធាវីការពារក្តីឲ្យជនជាប់ចោទ ឌុច ដោយវិធាន៨៩នៃវិធានផ្ទៃក្នុង គឺវានាំឲ្យមានការរំលោភបំពានមាត្រា២៩០នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធាន ៨៧(១) នៃវិធានផ្ទៃក្នុង ដែលតម្រូវឲ្យតុលាការត្រូវតែពិនិត្យភ័ស្តុតាងទាំងអស់មុននឹងឈានទៅដល់ការសម្រេច ។[២៤]

## ២) ការរួមបញ្ចូលគ្នានៃបទល្មើសនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាឧក្រិដ្ឋកម្មអន្តរជាតិដែលកំណត់ឡើងដោយច្បាប់អន្តរជាតិ ហើយឧក្រិដ្ឋកម្មនេះកំពុងត្រូវបានយកមកអនុវត្តក្នុងសំណុំរឿងរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ យោងតាមមាត្រា៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ៖

> ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាអំពើទាំងឡាយណាដែលវាយប្រហារជាទូទៅ ឬជាការរៀបចំប្រឆាំងទៅនឹងប្រជាជនស៊ីវិល ដោយមូលហេតុ ជាតិនយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ ។ អំពើទាំងនោះមានដូចជា៖
>
> - ការធ្វើមនុស្សឃាត
> - ការសម្លាប់រង្គាល
> - ការធ្វើឲ្យទៅជាទាសករ
> - ការនិរទេស
> - ការដាក់ក្នុងមន្ទីរឃុំឃាំង
> - ការធ្វើទារុណកម្ម
> - ការរំលោភលើផ្លូវភេទ
> - ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា
> - អំពើអមនុស្សធម៌ផ្សេងៗទៀត ។

ពាក់ព័ន្ធទៅនឹងបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះ សហព្រះរាជអាជ្ញាបានលើកឡើងថា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនីមួយៗដែលត្រូវបានចោទប្រកាន់នៅក្នុងករណីជនជាប់ចោទ កាំង ហ្គេក អ៊ាវ ហៅ ឌុច សុទ្ធតែមានធាតុផ្សំខុសៗគ្នា ដែលមិនមាននៅក្នុងបទល្មើសដទៃផ្សេងទៀតឡើយ" ។[២៥] អង្គជំនុំជម្រះសាលាដំបូងបានខកខានក្នុងការផ្តន្ទាទោសជនជាប់ចោទ ឌុច ឲ្យមានទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងទៅនឹងការដាក់ឲ្យទៅជាទាសករចំពោះអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីស-២១ ដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាអះអាងថា អង្គជំនុំជម្រះសាលាដំបូងគួរតែផ្តន្ទាទោសជនជាប់ចោទ ឌុច ដោយផ្តាច់ចេញពីគ្នារវាងបទល្មើសនៃការដាក់ឲ្យទៅជាទាសករ និងបទល្មើសនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលមាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយដាក់ទោសបូកបញ្ចូលរយៈពេលឃុំឃាំងឲ្យធ្ងន់ធ្ងរជាងនេះ មិនមែនបង្រួមចំនួននៃបទល្មើស ហើយបន្ថយរយៈពេលផ្តន្ទាទោសបែបនេះឡើយ ។ នៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍នេះ សហព្រះរាជអាជ្ញាបានលើកឡើង

---

[២៣] សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌទី៥ ។

[២៤] សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច កថាខណ្ឌទី៦៦និង៧០ ។

[២៥] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី១៣៧ ។

ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ និងអំពើអមនុស្សធម៌ផ្សេងៗទៀត គឺសុទ្ធតែមានធាតុផ្សំខុសៗគ្នាយ៉ាងពិតប្រាកដដែលមិនមាននៅក្នុងបទល្មើសនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ។

សហព្រះរាជអាជ្ញាបានលើកឡើងទាំងនៅក្នុងសារណាជាលាយលក្ខណ៍អក្សរ និងការដេញដោលនៅក្នុងសវនាការជាសាធារណៈថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសខាងផ្នែកច្បាប់ក្នុងការឲ្យនិយមន័យទៅលើពាក្យ "ការដាក់ឲ្យទៅជាទាសករ" ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ការដាក់ឲ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានគេឲ្យនិយមន័យថា "ជាការអនុវត្តនូវអំណាចណាមួយឬទាំងអស់ដែលភ្ជាប់ទៅនឹងសិទ្ធិលើកម្មសិទ្ធិទៅលើបុគ្គលណាមួយ" ។ អង្គជំនុំជម្រះបានយល់ខុសចំពោះធាតុផ្សំនៃពលកម្មដោយបង្ខំ ជាមួយនិយមន័យនៃការធ្វើឲ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។[២៦] ការឲ្យនិយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងមានលក្ខណៈចង្អៀតលើអត្ថន័យនៃការដាក់ឲ្យទៅជាទាសករ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ការដាក់ឲ្យទៅជាទាសករ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឈរលើមូលដ្ឋាននិយមន័យនៃពាក្យទាសភាពនៅក្នុងអនុសញ្ញាស្តីពីទាសភាពឆ្នាំ១៩២៦ ដែលបានផ្តល់និយមន័យទាសភាពថាជាស្ថានភាព ឬលក្ខខណ្ឌរបស់បុគ្គលម្នាក់ដែលអំណាចណាមួយ ឬគ្រប់អំណាចទាំងអស់ដែលភ្ជាប់ទៅនឹងសិទ្ធិលើកម្មសិទ្ធិត្រូវបានអនុវត្តលើគាត់ ។ សហព្រះរាជអាជ្ញាក៏បានលើកឡើងនៅក្នុងសារណាបណ្តឹងសាទុក្ខថា ៖

*នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះបានរកឃើញថាអំពើភាគច្រើនដែលបង្កើតបានជាការធ្វើឲ្យទៅជាទាសករ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានផ្តល់ចម្លើយ ដែលអំពើទាំងនោះមានដូចជាការត្រួតត្រាលើចលនារបស់ពួកអ្នកជាប់ឃុំឃាំង ការត្រួតត្រាលើបរិយាកាសជារូបវន្តបុគ្គល ការត្រួតត្រាតាមផ្លូវចិត្ត វិធាននានាដែលបានចាត់ឡើងដើម្បីទប់ស្កាត់ ឬដើម្បីធ្វើឲ្យញញើតកុំឲ្យមានការរត់គេចការគំរាមកំហែងដោយប្រើហិង្សា ឬការបង្ខិតបង្ខំ ការឋិតនៅក្រោមការគ្រប់គ្រង និងការបំពានដ៏សាហាវ ។ ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ក៏ធ្លាប់បានទទួលស្គាល់ថា ខ្លួនបានប្រើប្រាស់នូវការត្រួតពិនិត្យទៅលើជីវិត និងការស្លាប់របស់ពួកអ្នកជាប់ឃុំឃាំងនៅមន្ទីរស-២១ ។*[២៧]

ហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលទទួលយកនូវអំណះអំណាងនៃបណ្តឹងសាទុក្ខនេះ និងសូមឲ្យធ្វើសេចក្តីសម្រេចថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកច្បាប់ទៅលើនិយមន័យរបស់ខ្លួនស្តីពីការដាក់ឲ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងស្នើសុំឲ្យធ្វើសេចក្តីសម្រេចថាការធ្វើឲ្យទៅជាទាសករពុំតម្រូវឲ្យមានធាតុផ្សំពលកម្មដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្តនោះឡើយ ។

សហព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលបានស្រូបបញ្ចូលបទល្មើសរំលោភសេពសន្ថវៈថាជាអំពើទារុណកម្ម ដែលមានក្នុងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ សហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍ និងនៅក្នុងសវនាការជាសាធារណៈថា អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំផ្នែកច្បាប់ក្នុងការកំណត់បទចោទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំពោះការរំលោភសេពសន្ថវៈថាជាការធ្វើទារុណកម្មទៅវិញ ហើយខកខានមិនបានកាត់ក្តីជនជាប់ចោទឲ្យមានទោសពីបទរំលោភសេពសន្ថវៈដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយឡែកមួយផ្សេងនោះទេ ។[២៨] តាមយុត្តិសាស្ត្រអន្តរជាតិ ការរំលោភសេពសន្ថវៈអាចបង្កើតជាទម្រង់មួយនៃការធ្វើទារុណកម្ម "ដូចគ្នាទៅនឹងការធ្វើទារុណកម្មដែរ ការរំលោភសេពសន្ថវៈត្រូវបានគេប្រើប្រាស់ក្នុងគោលបំណងបំភិតបំភ័យ បន្ទាប

---

[២៦] *សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី២០១ ។*

[២៧] *សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី២០៧ ។*

[២៨] *សារណាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា កថាខណ្ឌទី១៩២ ។*



កាំង ហ្គេកអ៊ាវ ហៅ ឌុច (រូបថត : អ.វ.ត.ក)

បន្ថោក ការធ្វើឲ្យអាម៉ាស់មុខ ការប្រកាន់រើសអើង ការដាក់ទណ្ឌកម្ម ការត្រួតពិនិត្យ ឬបំផ្លិចបំផ្លាញជនណាម្នាក់»[២៩] ។ ថ្វីដ្បិតតែយុត្តិសាស្ត្រដែលថាអំពើរំលោភសេពសន្ថវៈអាចស្មើនឹងឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្មក៏ដោយ ក៏តុលាការអន្តរជាតិនានាកំណត់ដោយស្របគ្នាថា ប្រភេទបទល្មើសនៃការរំលោភសេពសន្ថវៈគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដែលដាច់ដោយឡែកពីការធ្វើទារុណកម្ម ទោះបីជាអំពើឧក្រិដ្ឋកម្មដដែលនេះស្មើគ្នានឹងការរំលោភសេពសន្ថវៈផង និងការធ្វើទារុណកម្មផងក៏ដោយ ។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ការរំលោភសេពសន្ថវៈបង្កើតបានទៅជាបទល្មើសដាច់ដោយឡែក និងត្រូវបានគេទទួលស្គាល់នៅក្នុង


ឌុច ក្នុងបន្ទប់សវនាការ (រូបថត : អ.វ.ត.ក)

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងទាំងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ការរំលោភសេពសន្ថវៈត្រូវបានគេហាមឃាត់តាំងពីយូរណាស់មកហើយនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងដែលត្រូវបានគេពិពណ៌នាថា គឺជាការឈឺចាប់ដ៏អាក្រក់ជាងគេបំផុតមួយក្នុងចំណោមការឈឺចាប់នានាដែលមនុស្សអាចបង្កទៅលើមនុស្សម្នាក់ផ្សេងទៀត ។

ហេតុដូច្នេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសខាងផ្នែកច្បាប់ ដោយធ្វើការស្រូបបញ្ចូលបទល្មើសនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំពោះការរំលោភសេពសន្ថវៈចូលទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំពោះការធ្វើទារុណកម្ម ហើយចាត់ទុកការរំលោភសេពសន្ថវៈជាការធ្វើទារុណកម្ម ។

សហមេធាវីការពារក្តីឲ្យជនជាប់ចោទ ឌុច មិនដាក់សារណាឆ្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងបញ្ហាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ដោយសារតែសហមេធាវីការពារក្តីឲ្យជនជាប់ចោទ ឌុច យល់ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមានអំណាចក្នុងការកាត់ទោសលើកូនក្តីរបស់ខ្លួនឡើយ ។ សហមេធាវីការពារក្តីឲ្យជនជាប់ចោទ ឌុច ក៏បានលើកឡើងដែរថា កូនក្តីរបស់ខ្លួនបានស្នើសុំមិនឲ្យធ្វើការឆ្លើយតបទៅនឹងការលើកឡើងពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលសហព្រះរាជអាជ្ញាបានលើកឡើង ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទបានធ្វើការឆ្លើយតបដោយសង្ខេបទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញា ដោយសង្កេតឃើញថា ជាទូទៅនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩របស់ព្រះរាជាណាចក្រកម្ពុជាបានបញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅក្នុងក្រមនោះ ហេតុដូច្នេះអង្គជំនុំជម្រះសាលាដំបូងមិនគួរធ្វើការបកស្រាយដោយយោងទៅតាមប្រព័ន្ធច្បាប់ខំមិនឡ នោះទេ ។ ឧទាហរណ៍ ដូចជាការយោងតាមយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិជាដើម ។ សហមេធាវីការពារក្តីរបស់ជនជាប់ចោទបានកត់សម្គាល់ថា ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មិនមានអានុភាពដោយផ្ទាល់ចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ដោយសារតែច្បាប់

[២៩] សារណាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា កថាខណ្ឌទី១៩៣ ។

នេះត្រូវបានអនុម័តនៅក្រោយយុត្តាធិការពេលវេលារបស់សាលាក្តីនេះ(១៩៧៥-១៩៧៩) ។ មិនតែប៉ុណ្ណោះ ក្រមនេះមិនបានផ្តល់ការណែនាំអំពីការចោទប្រកាន់ត្រួតគ្នាឡើយ ហើយក៏គ្មាននរណាម្នាក់ធ្លាប់ត្រូវបានកាត់ទោសតាមមាត្រា១៨៨នៃក្រមនេះពីមុនមកដែរ ។ មេធាវីការពារក្តីរបស់ ឌុច បានលើកឡើងថា ច្បាប់អន្តរជាតិមិនអនុវត្តចំពោះបុគ្គលនោះទេ គឺអនុវត្តចំពោះរដ្ឋតែប៉ុណ្ណោះ ទោះបីជាឧក្រិដ្ឋកម្មនោះស្ថិតនៅក្នុងយុត្តាធិការពេលវេលារបស់តុលាការក៏ដោយ ។ ហេតុដូច្នេះ មានតែមេដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យដែលជាអ្នកតំណាងរដ្ឋាភិបាលកម្ពុជានាសម័យនោះទេ ដែលគួរតែត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ សហមេធាវីការពារក្តីឲ្យជនជាប់ចោទ ឌុច មិនបានឆ្លើយតបទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលកើតមាននៅក្នុងមន្ទីរស-២១ ទាក់ទងទៅនឹងការរំលោភសេពសន្ថវៈនោះទេ ពីព្រោះបញ្ហានេះកូនក្តីរបស់ខ្លួនធ្លាប់បានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរួចមកហើយ ។

ឆ្លើយតបទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សម្រាប់ការដាក់ឲ្យទៅជាទាសករ មេធាវីការពារក្តីរបស់ ឌុច បានលើកឡើងថា បើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ការធ្វើឲ្យទៅជាទាសករ គឺតម្រូវឲ្យមានការបង្ខំឲ្យធ្វើការ ការដកហូតទ្រព្យសម្បត្តិ និងមានការដកហូតនូវសិទ្ធិជាសារវន្តរបស់ជនរងគ្រោះ ។ ដោយឡែកអ្នកទោសនៅមន្ទីរស-២១ មិនមានការបង្ខំឲ្យធ្វើការឡើយ ព្រោះនៅមន្ទីរស-២១ អ្នកទោសគឺត្រូវបានតម្រូវឲ្យផ្តល់ចម្លើយសារភាព រួចហើយនឹងត្រូវនាំយកទៅសម្លាប់ចោលតែប៉ុណ្ណោះ ។

## ៣) ការកំណត់ទោស

### *ក) ព្រះរាជអាជ្ញា ៖ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដាក់ទោសតិច និងបន្ធូរបន្ថយច្រើន*

ដោយផ្អែកទៅលើសភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានប្រព្រឹត្តនៅអំឡុងពេលដែលខ្លួនគ្រប់គ្រងនៅមន្ទីរសន្តិសុខស-២១ សហព្រះរាជអាជ្ញាបានស្នើសុំទៅអង្គជំនុំជម្រះសាលាដំបូងឲ្យផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារអស់មួយជីវិត ។ ក៏ប៉ុន្តែដើម្បីជាការទូទាត់សំណងឲ្យបានសមរម្យទៅនឹងការឃុំខ្លួនជនជាប់ចោទដោយខុសច្បាប់ពីសំណាក់តុលាការយោធានៃព្រះរាជាណាចក្រកម្ពុជានាពេលកន្លងមក សហព្រះរាជអាជ្ញាបានស្នើសុំទៅអង្គជំនុំជម្រះសាលាដំបូងឲ្យធ្វើការផ្តន្ទាទោសជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រឹមតែ៤៥ឆ្នាំវិញ ។ ម្យ៉ាងវិញទៀត ដោយបានពិចារណាទៅលើការសហការរបស់ជនជាប់ចោទជាមួយនឹងតុលាការ សហព្រះរាជអាជ្ញាក៏បានធ្វើការស្នើសុំតុលាការឲ្យកាត់បន្ថយទោសបន្ថែមប្រាំឆ្នាំទៀត ។ ជារួម សហព្រះរាជអាជ្ញាបានស្នើសុំអង្គជំនុំជម្រះឲ្យធ្វើការផ្តន្ទាទោសជនជាប់ចោទ ឌុច ដាក់ពន្ធនាគាររយៈពេល៤០ឆ្នាំ ។[៣០]

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានសម្រេចផ្តន្ទាទោសជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច រយៈពេល ៣៥ ឆ្នាំ ។ ការសម្រេចផ្តន្ទាទោសរយៈពេល៣៥ឆ្នាំរបស់អង្គជំនុំជម្រះសាលាដំបូងជាសិទ្ធិក្នុងការសម្រេចរបស់អង្គជំនុំជម្រះ ។ ក្រោយពីអង្គជំនុំជម្រះពិចារណាទៅលើកាលៈទេសៈទាំងអស់នៃរឿងក្តី រួមទាំងគោលការណ៍នៃការផ្តន្ទាទោសដែលពាក់ព័ន្ធអង្គជំនុំជម្រះសាលាដំបូងធ្វើការសន្និដ្ឋានជាឯកច្ឆន្ទថាពិតជាមានស្ថានសម្រាលទោសទៅលើរូបជនជាប់ចោទ ដែលអាចឲ្យអង្គជំនុំជម្រះកំណត់ផ្តន្ទាទោសដាក់ពន្ធនាគារក្នុងរយៈពេលមួយជាក់លាក់បាន ហើយស្ថានសម្រាលដែលត្រូវបានអង្គជំនុំជម្រះយកមកពិចារណាមាន ៖

- កិច្ចសហការរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាមួយនឹងអង្គជំនុំជម្រះ
- ការទទួលស្គាល់នូវការទទួលខុសត្រូវរបស់ជនជាប់ចោទ
- ការសម្តែងនូវវិប្បដិសារីរបស់ជនជាប់ចោទ និងការសុំអភ័យទោសចំពោះជនរងគ្រោះ ។[៣១]

---

[៣០] សាលក្រមសំណុំរឿង ០០១ កថាខណ្ឌទី៥៦៩ ។

[៣១] សាលក្រមសំណុំរឿង ០០១ កថាខណ្ឌទី៦២៨និង៦២៩ ។

ថ្វីដ្បិតតែអង្គជំនុំជម្រះបានពិចារណាទៅលើស្ថានសម្រាល នេះក៏ដោយ ក៏ប៉ុន្តែស្ថានសម្រាលទាំងនេះត្រូវបានកាត់បន្ថយវិញ ដោយសារតែ "ការស្នើសុំចុងក្រោយ" របស់ជនជាប់ចោទ កាំង ហ្កេក អ៊ាវ ហៅ ឌុច ទៅកាន់អង្គជំនុំជម្រះឲ្យដោះលែងខ្លួន ។[៣២] ការស្នើសុំរបស់ជនជាប់ចោទដូច្នេះ បានធ្វើឲ្យសាធារណជនទូទៅយល់ឃើញថា ការសម្តែងនូវវិប្បដិសារី និងការសុំអភ័យទោសចំពោះជនរងគ្រោះ ហាក់បីដូចគ្រាន់តែជាមធ្យោបាយរបស់ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅឌុច ដើម្បីទទួលបានការបន្ធូរបន្ថយទោសតែប៉ុណ្ណោះ ។ វាមិនបានផុសចេញពីទឹកចិត្តរបស់ជនជាប់ចោទរូបនេះឡើយ ។ អង្គជំនុំជម្រះក៏បានកត់សម្គាល់ឃើញថា ជនជាប់ចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលសាហាវឃោរឃៅយង់ឃ្នង និងគួរឲ្យតក់ស្លុតទៅលើជនរងគ្រោះយ៉ាងតិច១២.២៧៣នាក់ នៅក្នុងមន្ទីរស-២១អស់រយៈពេលដ៏យូរ ។[៣៣] ក្រោយពីបានធ្វើការពិចារណាទៅលើកាលៈទេសៈនៃសំណុំរឿងដូចដែលបានរៀបរាប់ខាងលើនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចផ្តន្ទាទោសជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដាក់ពន្ធនាគារ៣៥ឆ្នាំ ។

ក្រោយពេលសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានប្រកាសជាសាធារណៈ សហព្រះរាជអាជ្ញាបានធ្វើការប្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសាលក្រមនេះ ។ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយមិនបានផ្តន្ទាទោសជនជាប់ចោទឲ្យបានធ្ងន់ធ្ងរចំពោះឧក្រិដ្ឋកម្មជនជាប់ចោទបានប្រព្រឹត្ត ។ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមិនបានផ្តល់នូវការពន្យល់ណាមួយដែលជាមូលដ្ឋាននៅក្នុងការធ្វើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងការសម្រេចផ្តន្ទាទោស ឌុច ដាក់ពន្ធនាគារ៣៥ឆ្នាំនោះទេ ។ ម្យ៉ាងទៀតសហព្រះរាជអាជ្ញាបានអះអាងទាំងនៅក្នុងសារណាជាលាយលក្ខណ៍អក្សរ និងសវនាការជាសាធារណៈថា ការសម្រេចផ្តន្ទាទោសរបស់អង្គជំនុំជម្រះទៅលើជនជាប់ចោទ គឺបានផ្តល់ស្ថានសម្រាលទោសជ្រុលហួសហេតុដល់ជនជាប់ចោទ ។ សហព្រះរាជអាជ្ញាបានធ្វើការអះអាងបន្ថែមទៀតថា ការផ្តន្ទាទោសនេះមិនស័ក្តិសមទៅនឹងឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរដែលជនជាប់ចោទបានប្រព្រឹត្ត ។ សហព្រះរាជអាជ្ញាបានលើកឡើងនូវការប្រៀបធៀបការផ្តន្ទាទោសរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានាដើម្បីរំលេចឲ្យឃើញពីភាពមិនស៊ីសង្វាក់គ្នារវាងសភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលជនជាប់ចោទបានប្រព្រឹត្តនិងការផ្តន្ទាទោសលើជនជាប់ចោទ ។ សហព្រះរាជអាជ្ញាបានលើកឡើងនូវការផ្តន្ទាទោសដែលបានអនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលបានផ្តន្ទាទោសទៅលើឧក្រិដ្ឋកម្មដែលមានលក្ខណៈប្រហាក់ប្រហែលនឹងសំណុំរឿងរបស់ជនជាប់ចោទ ឌុច ដោយអំពើឧក្រិដ្ឋកម្មនោះបានប្រព្រឹត្តលើសពីរយៈពេល ១ឆ្នាំឡើងទៅ ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារជនជាប់ចោទជាមធ្យមមានរយៈពេល ៤៤ឆ្នាំ ។[៣៤] រីឯករណីនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដាវិញ ក្នុងករណីដែលឧក្រិដ្ឋកម្មប្រព្រឹត្តទៅលើប្រជាជនលើសពី១០០នាក់ឡើងទៅ ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារគិតជាមធ្យមចំនួន៣៧,៨៥ឆ្នាំ ។[៣៥] សហព្រះរាជអាជ្ញាក៏បានលើកឡើងពីការផ្តន្ទាទោសរបស់តុលាការព្រហ្មទណ្ឌពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ចំពោះជនជាប់ចោទដែលទទួលខុសត្រូវលើការបាត់បង់អាយុជីវិតប្រជាជនលើសពី១០០នាក់ ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារជាមធ្យម គឺរយៈពេល ៣៧ឆ្នាំ ។[៣៦] ក្នុងពេលសវនាការសាធារណៈ សហព្រះរាជអាជ្ញាបានធ្វើការបង្ហាញដ្យាក្រាមពីចំនួនប្រជាជនស៊ីវិលដែលរងគ្រោះស្លាប់បាត់បង់ជីវិតដោយសារអំពើឧក្រិដ្ឋកម្ម និងរយៈពេលដែល

---

[៣២] សាលក្រមសំណុំរឿង ០០១ កថាខណ្ឌទី៦២៩ ។

[៣៣] សាលក្រមសំណុំរឿង ០០១ កថាខណ្ឌទី៦៣០ ។

[៣៤] សារណាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៩៧ ។

[៣៥] សារណាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៩៧ ។

[៣៦] សារណាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៩៧ ។

ឧក្រិដ្ឋជនបានប្រព្រឹត្តនៅក្នុងឧក្រិដ្ឋកម្មរបស់បណ្តាតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ដើម្បីបង្ហាញឲ្យឃើញពីសភាពធ្ងន់ធ្ងរ និងព្រៃផ្សៃនៃឧក្រិដ្ឋកម្មដែលបានកើតឡើងនៅមន្ទីរស-២១ ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ឧក្រិដ្ឋកម្មដែលជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានប្រព្រឹត្តនោះ គឺមានសភាពធ្ងន់ធ្ងរ និងមានរយៈពេលយូរជាងបណ្តាឧក្រិដ្ឋកម្មអន្តរជាតិដទៃទៀតដែលគួរតែត្រូវបានផ្តន្ទាទោសធ្ងន់ធ្ងរជាងនេះ ។

**១) តើច្បាប់ណាដែលនឹងត្រូវយកមកកំណត់ទោសជនជាប់ចោទ ឌុច**

មានការខ្វែងយោបល់គ្នាយ៉ាងខ្លាំងរវាងសហព្រះរាជអាជ្ញា និងសហមេធាវីការពារក្តីរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ពាក់ព័ន្ធនឹងការប្រើប្រាស់ច្បាប់ក្នុងការកំណត់ទោសរបស់ជនជាប់ចោទ ឌុច ។ សហមេធាវីការពារក្តីរបស់ជនជាប់ចោទបានលើកឡើងថា ការទទួលបាននូវស្ថានសម្រាលទោសរបស់កូនក្តីខ្លួន គឺគប្បីតុលាការដាក់ទោសចន្លោះពី១៥ឆ្នាំដល់៣០ឆ្នាំដោយអនុលោមតាមមាត្រា៩៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ។ ដូចនេះការកំណត់ទោសចំពោះជនជាប់ចោទ ឌុច រយៈពេល៣៥ឆ្នាំពីសំណាក់អង្គជំនុំជម្រះសាលាដំបូង គឺជាការរំលោភលើមាត្រា៩៥ ។ មេធាវីការពារក្តីនៅតែប្រកាន់ជំហរស្នើសុំឲ្យតុលាការកំពូលប្រើប្រាស់ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ក្នុងការដាក់ទោសទៅលើជនជាប់ចោទ ។

សហព្រះរាជអាជ្ញាលើកឡើងថា តុលាការគប្បីប្រើប្រាស់ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលអនុញ្ញាតឲ្យចៅក្រមអាចដាក់ទោសពីកម្រិត៥ឆ្នាំ ទៅដល់អស់មួយជីវិត ដូចមានចែងក្នុងមាត្រា៣៩ នៃច្បាប់នេះ ។ ព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលប្រើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការកំណត់ទោសលើជនជាប់ចោទ ។

ប៉ុន្តែបញ្ហាដែលចោទឡើងគឺថា តើត្រូវប្រើប្រាស់ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រា៩៥ ឬប្រើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមាត្រា៣៩ ?

យោងតាមមាត្រា៦៦៨ កថាខណ្ឌ ២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ចែងថា “ក្នុងករណីដែលមានទំនាស់រវាងច្បាប់ និងបទបញ្ញត្តិផ្សេងៗជាមួយក្រមនេះ គេត្រូវអនុវត្តដោយអនុលោមតាមវិធានដែលមានចែងក្នុងគន្ថីទី១ នៃក្រមដដែលនេះ” ។ សហព្រះរាជអាជ្ញាបានលើកឡើងថា (មាត្រា៦៦៨ កថាខណ្ឌទី២ មិនគ្របដណ្តប់លើច្បាប់ព្រហ្មទណ្ឌដែលមានចរិតលក្ខណៈពិសេសនោះទេ មាត្រា៦៦៨ កថាខណ្ឌទី៣ នៃក្រមព្រហ្មទណ្ឌ២០០៩) ។ មានន័យថា បើច្បាប់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជាជាច្បាប់ព្រហ្មទណ្ឌមានចរិតពិសេសនោះ ចៅក្រមត្រូវប្រើច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកំណត់ក្នុងការផ្តន្ទាទោស ។ សំណួរបានចោទសួរឡើងថា “តើច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាច្បាប់ដែលមានចរិតពិសេសដែរឬទេ?” សហព្រះរាជអាជ្ញាយល់ថា ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាច្បាប់ដែលមានចរិតលក្ខណៈពិសេសដោយសារច្បាប់នេះបានកំណត់ពីរចនាសម្ព័ន្ធ



ទិដ្ឋភាពក្នុងបន្ទប់សវនាការ (រូបថត : អ.វ.ត.ក)

របស់តុលាការ និងការសម្រេចសេចក្តីតម្រូវឲ្យមានចៅក្រមខ្មែរ និងចៅក្រមបរទេស ។ បើយោងតាមមាត្រា២ កថាខណ្ឌ៣ នៃកិច្ចព្រមព្រៀងបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា "ក្នុងករណីធ្វើការកែប្រែច្បាប់របស់ខ្លួនតាមការចាំបាច់ត្រូវមានការពិភាក្សាគ្នាជាមុនរវាងភាគីទាំងពីរ" ។ ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាច្បាប់ជាប់កាតព្វកិច្ចមួយ ។ ដូចនេះរាល់ការកែប្រែខ្លឹមសារ ឬលុបចោលមាត្រាណាមួយនៃច្បាប់នេះត្រូវមានការពិភាក្សាគ្នាជាមុនរវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាច្បាប់ដែលមានអត្ថិភាពខ្ពស់ក្នុងការផ្តន្ទាទោសជនជាប់ចោទ ។

## ៤) បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី

### *ក) អំណះអំណាងរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី*

ក្រៅពីសហព្រះរាជអាជ្ញា និងសហមេធាវីការពារក្តីឲ្យជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏បានដាក់បណ្តឹងឧទ្ធរណ៍ទៅអង្គជំនុំជម្រះតុលាការកំពូលដើម្បីជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានប្រកាសមិនទទួលយកនូវការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងការបដិសេធចំពោះសំណើរបស់ជនរងគ្រោះទាក់ទងនឹងបញ្ហាសំណង ។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១ សរុបទាំងអស់មានចំនួន ៩០រូប[៣៧] ដែលតំណាងដោយមេធាវីការពារក្តីចំនួន ៤ក្រុម ហើយក្រុមនីមួយៗសុទ្ធតែមានមេធាវីតំណាងផ្សេងៗគ្នា ។ ក្នុងចំណោមសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំង៤ក្រុម គឺមានតែ៣ក្រុមប៉ុណ្ណោះ ដែលបានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ។

សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងបានសម្រេចច្រានចោលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងចំនួន២៨រូប ដោយផ្តល់ហេតុផលថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានច្រានចោលនោះខ្វះខាតភស្តុតាងជាឯកសារដែលបញ្ជាក់ថា ខ្លួនគឺជាជនរងគ្រោះដោយផ្ទាល់ពីមន្ទីរសន្តិសុខស-២១ ឬមន្ទីរសន្តិសុខស-២៤ និងខ្វះខាតភស្តុតាងដែលបញ្ជាក់ពីចំណងពិសេសនៃក្តីស្រឡាញ់រវាងអ្នកដែលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះដែលបានបាត់បង់ជីវិតនៅមន្ទីរសន្តិសុខទាំងពីរខាងលើនេះ ។[៣៨]

សហមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងបីក្រុមបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តសកម្មភាពក្រៅដែននៃអំណាចរបស់ខ្លួន ដោយប្រើប្រាស់នីតិវិធីទទួលស្គាល់ឋានៈរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរហូតទៅដល់ពីរដំណាក់កាល គឺការទទួលស្គាល់ដំបូងនៅពេលសវនាការបឋម និងក្រោយមកនៅពេលប្រកាសសាលក្រម ដែលវិធីសាស្ត្រនេះមិនមានចែងនៅក្នុងវិធានផ្ទៃក្នុងនោះទេ ។ អង្គជំនុំជម្រះសាលាដំបូងយកវិធីសាស្ត្រនេះមកប្រើដោយយោងទៅលើវិធាន ១០០ (១) នៃវិធានផ្ទៃក្នុងដែលបានចែងថា "អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចិត្តទៅលើការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រមរបស់ខ្លួន" ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ការប្រើប្រាស់វិធាន ១០០(១) របស់អង្គជំនុំជម្រះសាលាដំបូងបានធ្វើឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានការភាន់ច្រឡំថាខ្លួនបានទទួលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ ដោយសារខ្លួនបានអនុវត្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីនៅអំឡុងពេលសវនាការនៃអង្គសេចក្តីទាំងមូលរួចរាល់អស់ទៅហើយ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក៏បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានខកខានក្នុងការជូនដំណឹងឲ្យទាន់ពេលវេលាទៅដល់ភាគីទាំងឡាយដែលថាឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេនឹងត្រូវយកទៅពិចារណានៅពេលចុងបញ្ចប់នៃដំណើរការនីតិវិធី និងមិនបានជូនដំណឹងថា តើភស្តុតាងណាមួយដែលគួរតែយកមកសម្អាងបន្ថែមនោះទេ ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋរដ្ឋប្បវេណីបាន

[៣៧] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ប្រកាសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ករណី០០១ កថាខណ្ឌទី៦៣៨ ។

[៣៨] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ប្រកាសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ករណី០០១ កថាខណ្ឌទី៦៤៩ ។

បន្ថែមថា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់បទដ្ឋានខ្ពស់ហួសហេតុទៅលើការពិនិត្យនិងការបង្ហាញពីភស្តុតាងសម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។

### ១) សំណើសុំទាក់ទងទៅនឹងសំណង

អង្គជំនុំជម្រះសាលាដំបូងបានសម្រេចច្រានចោលរាល់សំណើសុំស្ទើរតែទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី ។ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ៖

*ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលមានឈ្មោះនៅក្នុងកថាខណ្ឌ៦៤៥ និង៦៥០ ពិតជាបានទទួលរងគ្រោះដែលជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋដែល កាំង ហ្កេកអ៊ាវ ហៅ ឌុច ត្រូវបានរកឃើញថាមានពិរុទ្ធភាព ។[៣៩] អង្គជំនុំជម្រះត្រូវចងក្រងសេចក្តីថ្លែងសុំអភ័យទោសទាំងអស់ និងការទទួលស្គាល់ការទទួលខុសត្រូវដែលជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច បានធ្វើនៅអំឡុងពេលសវនាការ ។ កម្រងនេះត្រូវដាក់លើគេហទំព័រផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅរយៈពេល១៤ថ្ងៃបន្ទាប់ពីសាលក្រមនេះចូលជាស្ថាពរ ។ អង្គជំនុំជម្រះបដិសេធចោលនូវការទាមទារផ្សេងៗទៀតទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី ។[៤០]*

ការសម្រេចផ្តល់សំណងពីរចំណុចខាងលើ មិនបានធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីពេញចិត្តឡើយ ដោយដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ បានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅអង្គជំនុំជម្រះតុលាការកំពូល ដើម្បីស្នើសុំសំណងចំនួន៩ប្រភេទដែលធ្លាប់ត្រូវបានច្រានចោលដោយអង្គជំនុំជម្រះសាលាដំបូង ។ សំណងទាំងនោះរួមមានការចែកផ្សាយយោបល់របស់ជនរងគ្រោះទៅលើពាក្យសុំអភ័យទោសរបស់ ឌុច បង្គាប់ឲ្យ ឌុច សរសេរលិខិតទៅរាជរដ្ឋាភិបាលកម្ពុជាស្នើសុំឲ្យធ្វើការសុំទោសជនរងគ្រោះក្នុងនាមជារដ្ឋ ចំណែកខ្លះនៃចំណូលពីការលក់សំបុត្រចូលសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងសារមន្ទីរជើងឯកយកមកចំណាយសម្រាប់ជាសំណងជំងឺចិត្តផ្សេងៗ សាងសង់បូជនីយដ្ឋាននៅមន្ទីរស-២១ និងស-២៤ កែប្រែគុកព្រៃសមកជាទីកន្លែងសម្រាប់រំឭកការចងចាំ ផ្គត់ផ្គង់មូលនិធិសម្រាប់ទស្សនកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណីមកកាន់បូជនីយដ្ឋានទាំងឡាយ ផ្តល់សេវាព្យាបាលសុខភាពផ្លូវកាយ និងផ្លូវចិត្តដល់ដើមបណ្តឹងរដ្ឋប្បវេណី ចែកចាយឯកសារតុលាការជាសំឡេងនិងវីដេអូ ដាក់ឈ្មោះអគារសាធារណៈចំនួន១៧ ដោយប្រើប្រាស់ឈ្មោះរបស់ជនរងគ្រោះ និងប្រារព្ធពិធីផ្សេងៗ ។[៤១]

ក៏ប៉ុន្តែការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២នេះត្រូវបានសហមេធាវីការពារក្តីរបស់ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច លើកឡើងថាកូនក្តីរបស់ខ្លួនគ្រាន់តែធ្វើការតាមបញ្ជារបស់មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ ដូច្នេះរបបកម្ពុជាប្រជាធិបតេយ្យគឺជាអ្នកដែលត្រូវទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មទាំងអស់នោះ ។ ហេតុនេះ កូនក្តីរបស់ខ្លួនមិនមានកាតព្វកិច្ចអ្វីត្រូវចេញសំណងទៅភាគីដើមបណ្តឹងរដ្ឋប្បវេណីឡើយ ។

## សេចក្តីថ្លែងចុងក្រោយរបស់ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច

ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច បានធ្វើសេចក្តីស្នើសុំនៅចុងបញ្ចប់នៃសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១ ថា ខ្លួនមិនមែនជាមេដឹកនាំជាន់ខ្ពស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយក៏មិនស្ថិតក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ។ ឌុច លើកឡើងថា “អ្នកទទួលខុសត្រូវខ្ពស់បំផុតគឺគេទេ មិនមែនខ្ញុំទេ” ។ “មេដឹកនាំនិងអ្នកទទួលខុសត្រូវខ្ពស់បំផុត គឺសំដៅយកអ្នកណាដែលមានសិទ្ធិបង្កើតមាគ៌ា កែប្រែមាគ៌ា និងលុបមាគ៌ា គឺគេ មិនមែនខ្ញុំ” ។ ឌុច បន្ត

---

[៣៩] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ប្រកាសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ករណី០០១ កថាខណ្ឌទី៦៨២ ។

[៤០] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ប្រកាសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ករណី០០១ កថាខណ្ឌទី៦៨៣ ។

[៤១] បណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងស្តីពីសំណងរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ F១៣ ។



កាំង ហ្កេកអ៊ាវ ហៅ ឌុច (រូបថត ៖ អ.វ.ត.ក)



ឌុច ស្តាប់ចៅក្រមអានសាលក្រម (រូបថត ៖ អ.វ.ត.ក)

ទៀតថា «បើកំណត់ពាក្យថាអចិន្ត្រៃយ៍មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាថាជាមេដឹកនាំជាន់ខ្ពស់ និងសម្រេចយកបុគ្គលទាំងឡាយដែលមានសិទ្ធិសម្រេចកម្ទេចថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះក៏គេ មិនមែនខ្ញុំ» ។ ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានបញ្ជាក់ថា ខ្លួនបានរស់រានមានជីវិតរហូតដល់ថ្ងៃនេះ គឺដោយសារតែខ្លួនគោរពគោលការណ៍នេះតាំងពីថ្ងៃ២០ កក្កដា ១៩៧១ យ៉ាងម៉ឺងម៉ាត់ ។ លើសពីនេះទៅទៀត ជនជាប់ចោទ ឌុច បានអះអាងថា ខ្លួនបានចូលរួមសហការយ៉ាងស្មោះត្រង់តាំងពីពេលដែលត្រូវចាប់ខ្លួនកាលពីឆ្នាំ១៩៩៩មកម្ល៉េះ ហើយជនជាប់ចោទបានពន្យល់អំពីមន្ទីរស-២១ ថាមានពិតប្រាកដមែន នៅខណៈពេលដែលមនុស្សម្នាបានស្តីបន្ទោសទៅលើរដ្ឋាភិបាលវៀតណាម ។ គោលជំហររបស់ខ្លួនផ្ទាល់ចំពោះប្រជាជនកម្ពុជា គឺសូមទទួលខុសត្រូវតាមផ្លូវច្បាប់ចំពោះអ្វីគ្រប់យ៉ាងដែលបានកើតឡើងនៅមន្ទីរស-២១ និងការខូចខាតខាងរូបរាងកាយរបស់ជនរងគ្រោះ ហើយខ្លួនបានស្នើសុំការអភ័យទោស ។ ជនជាប់ចោទបានអះអាងថា អតីតកម្មាភិបាលខ្មែរក្រហម និងមន្ត្រីជាន់ខ្ពស់ខ្មែរក្រហមនឹងនៅរក្សានូវគោលជំហរយ៉ាងរឹងមាំថាពួកគេចូលរួមជាមួយខ្មែរក្រហមដើម្បីរំដោះប្រទេសជាតិរបស់ខ្លួន ក៏ប៉ុន្តែមាគ៌ាបក្ស គឺជាមាគ៌ាឧក្រិដ្ឋ ។ កម្មាភិបាលម្នាក់ៗដែលហ៊ានលះបង់អ្វីៗទាំងអស់ដើម្បីប្រទេសជាតិរបស់ខ្លួនត្រូវបានជាប់ឃុំឃាំងដើម្បីអនុវត្តមាគ៌ាឧក្រិដ្ឋរបស់បក្ស ។ ជនជាប់ចោទនិយាយថា ខ្លួនមានជំនឿជឿជាក់យ៉ាងមុតមាំថា អង្គជំនុំជម្រះតុលាការកំពូល គឺស្វែងរកការពិតសម្រាប់ប្រជាជនកម្ពុជាជនរងគ្រោះកម្មាភិបាល និងកងទ័ពទាំងអស់ ដើម្បីការរស់នៅដោយសន្តិភាពរបស់ប្រជាជនកម្ពុជា ។

នៅក្នុងសំណើសុំចុងក្រោយរបស់ខ្លួន ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានស្នើសុំទៅអង្គជំនុំជម្រះតុលាការកំពូលថា បើយោងទៅលើការរៀបរាប់ខាងលើរបស់ខ្លួន អង្គជំនុំជម្រះគួរតែរកឃើញថា ខ្លួនមិនស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។[៤៣]

## សន្និដ្ឋាន

សាលដីកាលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿង ០០១ មានសារសំខាន់ខ្លាំងណាស់សម្រាប់ជនរងគ្រោះ ។ អង្គជំនុំជម្រះតុលាការកំពូលគ្រោងនឹងប្រកាសសាលដីកានេះ នៅត្រឹមចុងឆ្នាំ២០១១ខាងមុខ ។ សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនឹងឆ្លើយតបទៅនឹងការប្តឹងសុំរបស់ភាគីទាំងអស់ដែលបានលើកឡើងនៅក្នុងអំឡុងពេលសវនាការ រួមមានបញ្ហាយុត្តាធិការបុគ្គលដែលត្រូវបានលើកឡើងដោយភាគីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ការកំណត់ទោសដែលត្រូវបានលើកឡើងដោយភាគីសហព្រះរាជអាជ្ញា និងការស្នើសុំឲ្យមានការផ្តល់សំណង និងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង០០១ នឹងក្លាយជាសេចក្តីសម្រេចចុងក្រោយលើកដំបូងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលជនរងគ្រោះនិងប្រជាជនកម្ពុជារងចាំអស់រយៈកាលជាង៣២ឆ្នាំ ។

**ពិនិត្យនិងផ្ទៀងផ្ទាត់ដោយ ខាន់ថាន់ ពៅដារ៉ា**

---

[៤៣] សេចក្តីថ្លែងចុងក្រោយរបស់ ឌុច នៅក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍របស់អង្គជំនុំជម្រះតុលាការកំពូល កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១

# មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ៖ (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល៖ dccam@online.com.kh

គេហទំព័រ៖ www.dccam.org ឬ www.cambodiatribunal.org



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ John D. and Catherine T. MacArthur Foundation ។




**ឌី សុជាតា**

**សុជាតា** ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ សិក្សាជាភាសាអង់គ្លេសនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**គីម ម៉ារីយ៉ាន**

**ម៉ារីយ៉ាន** បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ម៉ារីយ៉ាន ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិត ឆ្នាំ២០១០ ។



**លីម ជ័យទត្ត**

**ជ័យទត្ត** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ជ័យទត្ត ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិត ឆ្នាំ២០១០ ។



**ចាន់ ប្រាថ្នា**

**ប្រាថ្នា** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ប្រាថ្នា សព្វថ្ងៃកំពុងត្រៀមប្រឡងសិក្សាវិជ្ជាជីវៈមេធាវី នៅកម្ពុជា ។



# កាំង ហ្គេកអ៊ាវ

(រូបថត ៖ ស្នូត អ៊ីសិត / ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិ ខែតុលា ឆ្នាំ២០១១